

ILR Global Labor Institute

# តើវាជាឧត្តមភាពឬ?

## ការបំផ្លិចបំផ្លាញដោយអាកាសធាតុមកលើវិស័យសម្លៀកបំពាក់ និង ផលប៉ះពាល់របស់វាចំពោះកម្មករ

### សង្ខេបអំពីកម្មករនៅប្រទេសកម្ពុជា

### សេចក្តីផ្តើម

ការកើនឡើងកម្តៅនិងទឹកជំនន់ខ្លាំងត្រូវបានផ្សារភ្ជាប់ជាមួយនឹងការប្រែប្រួលអាកាសធាតុពាសពេញពិភពលោករួមទាំងនៅប្រទេសកម្ពុជា ។ ពួកវារំខានការរស់នៅរបស់កម្មករកាត់ដេរ ហើយអាចបង្កឲ្យមានជំងឺ ។ ពួកវាក៏រំខាន ឬបន្ថយល្បឿនការងារនៅក្នុងរោងចក្រកាត់ដេរផងដែរ។ កម្តៅ និងទឹកជំនន់ខ្ពស់នឹងធ្វើឲ្យនិយោជក និងកម្មករត្រូវបាត់បង់ប្រាក់ចំណូលរាប់រយពាន់លានដុល្លារ និងការងាររាប់លានកន្លែងត្រឹមឆ្នាំ 2030 និង 2050 ។

នៅក្នុងរបាយការណ៍នេះពីវិទ្យាស្ថានការងារសកលនៃសកលវិទ្យាល័យ Cornell និង Schroders — ក្រុមហ៊ុនវិនិយោគសកលមួយ — សំណួរចម្បងរបស់យើងគឺ៖ តើមានហានិភ័យអ្វីខ្លះ សម្រាប់កម្មករកាត់ដេរសម្លៀកបំពាក់ពីការប្រែប្រួលអាកាសធាតុ ហើយតើវានឹងធ្វើឲ្យខូចខាតសេដ្ឋកិច្ចដល់កម្រិតណា?

ដើម្បីឆ្លើយនឹងសំណួរនេះ យើងប្រៀបធៀបពីការប៉ាន់ស្មានសម្រាប់សីតុណ្ហភាព និងទឹកជំនន់នាពេលអនាគតនៅក្នុងមជ្ឈមណ្ឌលផលិតកម្មសម្លៀកបំពាក់ចំនួន 30 នៅជុំវិញពិភពលោក ។ បន្ទាប់មក យើងពិនិត្យមើលយ៉ាងជិតដល់នូវផលប៉ះពាល់សម្រាប់កម្មករកាត់ដេរសម្លៀកបំពាក់នៅក្នុងប្រទេសចំនួន 4 គឺ បង់ក្លាដែស កម្ពុជា ប៉ាគីស្ថាន និងវៀតណាម ។ ហើយយើងក្រឡេកមើលពីរបៀបដែលការបំផ្លិចបំផ្លាញដោយអាកាសធាតុ ដែលកំពុងជះឥទ្ធិពលដល់កម្មករកាត់ដេរសម្លៀកបំពាក់។

បន្ទាប់មកទៀត យើងប្រៀបធៀបច្បាប់ និងបទប្បញ្ញត្តិអំពីកម្ដៅ ច្បាប់ឈប់សម្រាកឈឺ និងការគាំពារសង្គមនៅក្នុងប្រទេសទាំងបួននេះ ។ ចុងបញ្ចប់ យើងស្នើឲ្យមានការផ្លាស់ប្ដូរផ្សេងៗដែលសហជីព និយោជក រដ្ឋាភិបាល អ្នកបញ្ជាទិញសម្លៀកបំពាក់ និងវិនិយោគិន គួរតែអនុវត្តនាពេលឥឡូវនេះ ដើម្បីការពារកម្មករ និងការផលិតសម្លៀកបំពាក់ពីការកើនកម្ដៅ និងទឹកជំនន់ខ្លាំង ។

## 1.0 ផលប៉ះពាល់នៃកម្ដៅ និងទឹកជំនន់ខ្លាំង

កម្ដៅនិងសំណើមខ្ពស់រួមបញ្ចូលគ្នាធ្វើឲ្យការងារ និងជីវិតកម្មករមានការលំបាក ។ ពួកវាអាចកាត់បន្ថយយ៉ាងខ្លាំងក្នុងផលិតភាពនៅកន្លែងធ្វើការ និងប្រាក់ចំណូលកម្មករ ហើយពួកវាអាចបង្កគ្រោះថ្នាក់ដល់សុខភាពកម្មករ និងក្រុមគ្រួសាររបស់ពួកគេ ។ "ភាពតានតឹង ឬស្ត្រេសដោយសារកម្ដៅ" នៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ ឬស្បែកជើងអាចនាំឲ្យអស់កម្លាំង ដួលសន្លប់ និងក៏បណ្ដាលឲ្យមានជំងឺដាច់សរសៃឈាមខួរក្បាលផងដែរ ។
"សន្ទស្សន៍កម្ដៅ"ពាក្យកាត់ហៅថា (WBGT) រួមបញ្ចូល កម្ដៅ និងសំណើមជាលេខតែមួយ ។ លេខនៃសន្ទស្សន៍ កម្ដៅជាធម្មតាទាបជាងសីតុណ្ហភាពធម្មតា ប៉ុន្តែសន្ទស្សន៍កម្ដៅ 30 អង្សាសេ និងខ្ពស់ជាងនេះមានន័យថា ភាពតានតឹងដោយសារកម្ដៅក៏ខ្ពស់ជាងមុនដែរសម្រាប់កម្មករ ។ អ្នកជំនាញនិយាយថា នៅប្រហែល 30 អង្សាសេ នៃ WBGT កម្មករកាត់ដេរសម្លៀកបំពាក់គួរតែសម្រាករយៈពេល 30 នាទីក្នុងរយៈពេលរាល់មួយម៉ោងម្ដង ។ នៅ 35 អង្សាសេនៃ WBGT និងខ្ពស់ជាងនេះ កម្មករអាចមានបញ្ហាសុខភាពធ្ងន់ធ្ងរ ទោះបីជាពួកគេកំពុងធ្វើការតិចតួចក៏ដោយ ។[1]

តារាងខាងក្រោមប្រៀបធៀបចំនួនថ្ងៃក្នុងឆ្នាំ 2030 នៃភាពតានតឹងដោយសារកម្ដៅ (ដែលមាន WBGT លើសពី 30.5 អង្សាសេ) នឹងខ្ពស់សម្រាប់កម្មករនៅតាមទីក្រុងដែលផលិតសម្លៀកបំពាក់ និងស្បែកជើង ។ ទីក្រុង ការ៉ាជី នឹងមានថ្ងៃច្រើនបំផុតជាមួយនឹងកម្ដៅ និងសំណើមខ្ពស់៖ 190 ថ្ងៃ ក្នុងឆ្នាំ 2030 និង 203 ថ្ងៃ ក្នុងឆ្នាំ  2050 ។ ទីក្រុងផ្សេងទៀតដែលមាននៅក្នុងរបាយការណ៍របស់យើងក៏នឹងខ្ពស់ផងដែរដូចជា៖ ទីក្រុងដាក្កា ឈីតាហ្គង់ ហូជីមិញ និងភ្នំពេញ ។

**តារាងទី 1៖** ចំនួនថ្ងៃដែលមានភាពតានតឹងដោយសារកម្ដៅខ្លាំង ក្នុងឆ្នាំ 2030 និង 2050 តាមទីក្រុង

| ទីក្រុងផលិតសំលៀកបំពាក់ | | តើមានភាពតានតឹងដោយសារកម្ដៅខ្លាំងប៉ុន្មានថ្ងៃក្នុងមួយឆ្នាំ? | |
|---|---|---|---|
| ទីក្រុង | ប្រទេស | 2030* | 2050 |
| ការ៉ាជី | ប៉ាគីស្ថាន | 190 | 203 |
| កូឡុំបូ | ស្រីលង្កា | 145 | 158 |
| ម៉ាណាហ្គា | នីការ៉ាហ្គា | 133 | 151 |
| ព័រលេ្វ | ម៉ូរីស | 104 | 104 |
| ដាក្កា | បង់ក្លាដែស | 65 | 105 |
| យ៉ងហ្គូន | មីយ៉ាន់ម៉ា | 59 | 92 |
| ដេលី | ឥណ្ឌា | 55 | 75 |

[1] ការប៉ាន់ស្មានរបស់យើងគឺផ្អែកលើសេណារីយ៉ូអាកាសធាតុនៃមាគ៌ាសង្គមសេដ្ឋកិច្ចរួម (SSP) 2-4.5 ។ សេណារីយ៉ូនាពេលអនាគតនេះគឺ "ឈរលើមាគ៌ាកណ្ដាល" — មិនមានសុទិដ្ឋិនិយម និងមិនទុទិដ្ឋិនិយម ហើយសន្មតថាសីតុណ្ហភាពពិភពលោកនឹងកើនឡើងខ្ពស់ជាងកម្រិតដែលបានកំណត់នៅឯកិច្ចចរចារ COP នៅទីក្រុងប៉ារីស ក្នុងឆ្នាំ 2016 ។

| | | | |
|---|---|---|---|
| ហូជីមិញ | វៀតណាម | 55 | 98 |
| ឈីតាហ្គង់ | បង់ក្លាដែស | 50 | 85 |
| សាន់សាល់វ៉ាឌ័រ | អែលសាល់វ៉ាឌ័រ | 42 | 57 |
| បាងកក | ថៃ | 42 | 75 |
| ភ្នំពេញ | កម្ពុជា | 41 | 75 |

យើងមានទិន្នន័យរបស់អង្គការពលកម្មអន្តរជាតិ (ILO) ពីកម្មវិធី Better Work នៅកម្ពុជា ។ អង្គការ ILO ធ្វើសវនកម្មលើរោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងដែលនាំចេញទាំងអស់ ហើយពិនិត្យសីតុណ្ហភាព និងខ្យល់ចេញចូលនៅពេលរសៀល នៅពេលដែលវាក្តៅបំផុត ។ សីតុណ្ហភាពលើសពី 32 អង្សាសេ នៅក្នុងរោងចក្រ គឺខ្ពស់ពេក ដែលជាការបំពាន ។ ពីការចុះពិនិត្យមើលរបស់អង្គការ ILO ចំនួន 3,000 ដងទៅរោងចក្រកាត់ដេរសម្លៀកបំពាក់នៅកម្ពុជាចន្លោះឆ្នាំ 2015 ដល់ 2022 យើងមើលឃើញថា៖

- កម្មករនៅក្នុងរោងចក្រមួយក្នុងចំណោមរោងចក្រប្រាំ ក្នុងអំឡុងពេលប្រាំពីរឆ្នាំនេះបានធ្វើការនៅពេលថ្ងៃដែលសីតុណ្ហភាពខាងក្នុងអគារលើសពី 35 អង្សាសេ ។
- ជិតពីរភាគបី (64 ភាគរយ) នៃរោងចក្រមានសីតុណ្ហភាពខាងក្នុងអគារ លើសពីស្តង់ដារកម្តៅរបស់អង្គការ ILO ហើយ 69 ភាគរយនៃរោងចក្រទាំងនោះមានសីតុណ្ហភាពនៅ *ខាងក្នុង* រោងចក្រខ្ពស់ជាងសីតុណ្ហភាពនៅខាងក្រៅរោងចក្រ ។

ទិន្នន័យនេះបង្ហាញថា រោងចក្រនៅកម្ពុជាមានភាពប្រសើរឡើងក្នុងរយៈពេលកន្លងទៅនេះ ប៉ុន្តែនៅមានសភាពយឺតយ៉ាវ ។ យ៉ាងណាមិញ អង្គការ ILO មិនបានប្រមូលទិន្នន័យនេះនៅក្នុងបណ្តារោងចក្រ នៅក្នុងកម្មវិធី Better Work សម្រាប់ប្រទេសបង់ក្លាដែស ប៉ាគីស្ថាន និងវៀតណាមទេ ។

នៅក្នុងរបាយការណ៍របស់យើង យើងប៉ាន់ប្រមាណពីផលប៉ះពាល់នៃកម្តៅខ្ពស់សម្រាប់កម្មករនៅក្នុងរោងចក្រកាត់ដេរ នៅឆ្នាំ 2030 និង 2050 ។ ប្រសិនបើរោងចក្រមិនត្រូវបានធ្វើឲ្យត្រជាក់នៅពេលថ្ងៃក្តៅទេ ផលិតភាពរបស់កម្មករនឹងធ្លាក់ចុះ ។ កម្មករអាចផលិតបានតិចជាង 1 ទៅ 2 ភាគរយ សម្រាប់រាល់ការកើនឡើងនៃសីតុណ្ហភាព 1 អង្សាសេនៃ WBGT ។ ឧទាហរណ៍៖ 32 អង្សាសេនៃ WBGT មានន័យថា កម្មករផលិតបានតិចជាង 7 ទៅ 14 ភាគរយ នៅថ្ងៃនោះ ។ នេះកាត់បន្ថយប្រាក់ចំណូលសម្រាប់និយោជក និងកម្មករ ។ ឧស្សាហកម្មកាត់ដេរនឹងកើនឡើងក្នុងអត្រាយឺត ហើយបង្កើតការងារថ្មីៗតិចជាងមុន ។ សម្រាប់ប្រទេសបង់ក្លាដែស កម្ពុជា ប៉ាគីស្ថាន និងវៀតណាម យើងបានគណនាចំនួនប្រាក់ចំណូល (ចំណូលពីការនាំចេញ) និងចំនួនការងារដែលឧស្សាហកម្មនឹងបាត់បង់ ប្រសិនបើកម្មករ និងរោងចក្រមិនត្រូវបានការពារពីកម្តៅ និងសំណើមខ្ពស់ទេនោះ ។

ទឹកជំនន់ក៏នឹងកាន់តែខ្ពស់នៅពេលអនាគតផងដែរ ។ នៅក្នុងរបាយការណ៍របស់យើង យើងប៉ាន់ប្រមាណថា តើថ្ងៃធ្វើការងារប៉ុន្មានដែលនឹងត្រូវបាត់បង់សម្រាប់ទឹកជំនន់នៅឆ្នាំ 2030 និង 2050 នៅក្នុងប្រទេសទាំងបួន ។ នៅក្នុងផែនទីខាងក្រោម យើងបង្ហាញពីចំនួនរោងចក្រ (ចំណុចពណ៌ខៀវ) នៅក្នុងប្រទេសកម្ពុជា នឹងត្រូវរងផលប៉ះពាល់ដោយទឹកជំនន់ ពីទឹកភ្លៀង និងទន្លេដែលមានកម្រិតខ្ពស់ (ពណ៌ក្រហម) និងជំនន់សមុទ្រ (ពណ៌មាស) ក្នុងឆ្នាំ 2030 ។



Phnom Penh, Cambodia. Photo credit: Cornell GLI

ជំនន់ដោយទឹកទន្លេ ទឹកភ្លៀង និងទឹកសមុទ្រ នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ក្នុងឆ្នាំ 2030 ។



ផ្ទាំទឹកជំនន់ដ៏អាក្រក់នៅក្នុងប្រទេសបង់ក្លាដែសមានន័យថា 32 ភាគរយនៃរោងចក្រនាំចេញសម្លៀកបំពាក់ទាំងអស់អាចត្រូវបានរំខានអស់រយៈពេលជាច្រើនថ្ងៃ ដោយសារទឹកជំនន់ទន្លេ និងឆ្នេរសមុទ្រដែលមានកម្ពស់ 0.5 ម៉ែត្រ ឬលើសនេះ ។ នៅប្រទេសវៀតណាម រោងចក្រ 31 ភាគរយមានហានិភ័យ ។ នៅកម្ពុជា ហានិភ័យគឺទាបជាង៖ 11 ភាគរយនៃរោងចក្រទាំងអស់ ។ នៅក្នុងប្រទេសប៉ាគីស្ថាន វាមានកម្រិតទាបបំផុត ៖ 5 ភាគរយ ។

យើងគណនាការខាតបង់ដែលអាចកើតមាននៅក្នុងប្រាក់ចំណូលនាំចេញ (គិតជាដុល្លារអាមេរិក) សម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់នៅក្នុងប្រទេសនីមួយៗខាងក្រោមសម្រាប់ពីរឆ្នាំគឺ៖ ឆ្នាំ 2030 និង 2050 ។

.

**តារាងទី 2៖** ប្រាក់ចំណូលនាំចេញសម្លៀកបំពាក់ "ការខាតបង់" តាមប្រទេស ឆ្នាំ 2030 និង 2050 ។

| ប្រទេស | ឆ្នាំ | "ការខាតបង់" នៃប្រាក់ចំណូលដោយគ្មានការសម្របខ្លួន (គិតជាពាន់លានដុល្លារអាមេរិក) | ការប្រែប្រួល (ភាគរយ) |
|---|---|---|---|
| បង់ក្លាដែស | 2030 | -26.8 | -21.95% |
| | 2050 | -711.3 | -68.51% |
| កម្ពុជា | 2030 | -6.8 | -18.94% |
| | 2050 | -156.3 | -66.40% |
| ប៉ាគីស្ថាន | 2030 | -7.6 | -30.94% |
| | 2050 | -180.7 | -80.52% |
| វៀតណាម | 2030 | -24.8 | -21.20% |
| | 2050 | -378.3 | -65.74% |

**តារាងទី 3៖** ការងារកាត់ដេរសម្លៀកបំពាក់ "ការបាត់បង់" តាមប្រទេស ក្នុងឆ្នាំ 2030 និង 2050 ។

| ប្រទេស | ឆ្នាំ | "ការបាត់បង់" ការងារ ដោយគ្មានការសម្របខ្លួន | ការប្រែប្រួល (ជាភាគរយ) |
|---|---|---|---|
| បង់ក្លាដែស | 2030 | -255,067 | -5.29% |
| | 2050 | -1,272,594 | -20.17% |
| កម្ពុជា | 2030 | -52,944 | -5.63% |
| | 2050 | -556,545 | -32.76% |
| ប៉ាគីស្ថាន | 2030 | -296,915 | -8.65% |
| | 2050 | -1,854,537 | -34.56% |
| វៀតណាម | 2030 | -353,301 | -7.53% |
| | 2050 | -4,957,201 | -42.38% |

ប្រាក់ចំណូល "ដែលខាតបង់" នាពេលអនាគតដោយសារតែកម្ដៅ និងទឹកជំនន់ខ្លាំងដែលមានទំហំទឹកប្រាក់ 65.89 ពាន់លានដុល្លារក្នុងឆ្នាំ 2030 សម្រាប់ប្រទេសទាំងបួន ដែលបានបូកបញ្ចូលគ្នា ។ នោះគឺមាន 22 ភាគរយ ដែលទាបជាងចំណូលនៃការនាំចេញ ប្រសិនបើឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់បានវិនិយោគយ៉ាងឆាប់រហ័ស ដើម្បីការពារកម្មករពីការឡើងកម្ដៅ និងការជន់លិចខ្លាំង ជាឧទាហរណ៍ដោយមានការបំពាក់ប្រព័ន្ធម៉ាស៊ីនត្រជាក់របស់រោងចក្រ ការធ្វើឲ្យកាន់តែប្រសើរនៃលំហូរខ្យល់ និងការទប់ទល់នឹងទឹកជំនន់ ជាដើម ។ ការវិនិយោគបែប "សម្របខ្លួន" ទាំងនេះនឹងជួយនិយោជក កម្មករ និងក្រុមគ្រួសាររបស់ពួកគេ ទប់ទល់នឹងការខាតបង់ និងការខូចខាតពីការប្រែប្រួលអាកាសធាតុ ។

ចំនួនការងារដែលបាត់បង់នៅក្នុងប្រទេសទាំងបួននឹងមាន 958,227 កន្លែងនៅក្នុងឆ្នាំ 2030 ។

ការបាត់បង់សម្រាប់ឆ្នាំ 2050 នឹងកើនឡើងកាន់តែច្រើន ដោយសារសីតុណ្ហភាពកើនឡើង ហើយទឹកជំនន់កាន់តែធ្ងន់ធ្ងរ ។ ការនាំចេញសម្លៀកបំពាក់នៅក្នុងប្រទេសទាំងបួននេះនឹងទាបជាង 69 ភាគរយ ហើយនឹងមានការងារតិចជាង 8.6 លានកន្លែង ប្រសិនបើនិយោជក រដ្ឋាភិបាល និងអ្នកបញ្ជាទិញមិនធ្វើការវិនិយោគលើការបន្សាំ ឬសម្របនឹងអាកាសធាតុទេនោះ ។

## 2.0 តើការបំផ្លិចបំផ្លាញដោយអាកាសធាតុមានន័យយ៉ាងណាសម្រាប់កម្មករ ?

ទឹកជំនន់នៅក្នុងសង្កាត់របស់កម្មករអាចបណ្តាលឲ្យមានការពន្យារពេលក្នុងការទៅធ្វើការងារ ។ កម្មករខ្លះនៅទីក្រុងដាក្កា និងឈីតាហ្គង់ ប្រើទូកទៅធ្វើការ ។ ការបាត់បង់ម៉ោងសម្រាប់កម្មករមានន័យថា បាត់បង់ប្រាក់ឈ្នួល ។ ហើយទឹកជំនន់អាចនាំឲ្យមានជំងឺដូចជា ចេញកន្ទួល រាគ និងគ្រុនឈាម ។ កម្តៅខ្លាំងអាចនាំឲ្យឈឺក្បាល ខ្សោះជាតិទឹក វិលមុខ និងដួលសន្លប់ ។ នេះអាចមានន័យថា ថ្លៃព្យាបាលសុខភាពខ្ពស់ជាងមុន និងបាត់បង់ប្រាក់ឈ្នួល ។

នៅទីក្រុងដាក្កា ប្រទេសបង់ក្លាដែស អ្នកស្រាវជ្រាវនៃសាកលវិទ្យាល័យ BRAC បានជួបជាមួយកម្មករ និងអ្នកគ្រប់គ្រងរោងចក្រ ដើម្បីស្តាប់អំពីបញ្ហាកម្តៅ និងទឹកជំនន់។ ការព្រួយបារម្ភដ៏ធំបំផុតរបស់កម្មករនៅក្នុងការប្រជុំក្រុមទាំងអស់គឺការបាត់បង់ប្រាក់ឈ្នួល ហើយមានមនុស្សជាច្រើនបាននិយាយថា ពួកគេ "ប្រឹងសម្របខ្លួន" នៅក្នុងខែឧសភា មិថុនា និងកក្កដា នៅពេលដែលមានសីតុណ្ហភាព និងសំណើមខ្ពស់ ហើយចំណែកឯទីក្រុងក៏កំពុងជន់លិចផងនោះ ។

កម្មករក៏បានពិពណ៌នាអំពីការតស៊ូ ដើម្បីសម្រេចបាននូវគោលដៅផលិតកម្មប្រចាំថ្ងៃ ដែលគ្មានការកែសម្រួល ដើម្បីអាចសម្រេចបានសម្រាប់កម្តៅដ៏ខ្ពស់នេះ ។ កម្មករបានរាយការណ៍ថា ពួកគេត្រូវបានចុះបញ្ជីលើប្រាក់ឈ្នួល (សម្គាល់ថាយឺតយ៉ាវ) ទោះបីជាពួកគេយឺតប៉ុន្មាននាទីដោយសារទឹកជំនន់ ឬត្រូវបានបដិសេធចំពោះច្បាប់ឈប់សម្រាកឈឺដែលមានប្រាក់ឈ្នួលប្រសិនបើពួកគេធ្លាក់ខ្លួនឈឺ ។ ហើយកម្មករបានរាយការណ៍ថា ពេលខ្លះក៏មានការខកខានការធ្វើការងារបីថ្ងៃពេញក្នុងមួយខែដោយសារជំងឺពីកម្តៅ និងទឹកជំនន់ក្នុងខែដែលក្តៅបំផុត និងភ្លៀងធ្លាក់ខ្លាំងបំផុតក្នុងឆ្នាំ ។ នេះមានន័យថា បាត់បង់ប្រាក់ឈ្នួល BDT 1,200 – 1,500 (USD 11 – 14) ក្នុងមួយខែ ឬច្រើនជាង 10 ភាគរយនៃប្រាក់ចំណូលរបស់ពួកគេ ។

ចុងក្រោយ កម្មករនៅប្រទេសបង់ក្លាដែសបានប៉ាន់ប្រមាណថា ពួកគេចំណាយអស់ BDT 3,500 (USD 31) សម្រាប់ថ្នាំពេទ្យ និង 2,000 BDT (18 ដុល្លារ) សម្រាប់អគ្គិសនីនៅផ្ទះក្នុងខែក្តៅបំផុត នៅពេលដែលពួកគេប្រើកង្ហារជាប្រចាំដើម្បីជួយឲ្យពួកគេគេងលក់ ។ កម្មករបានរាយការណ៍ពីការខ្ចីប្រាក់ដោយដាក់បញ្ចាំទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងបង់អត្រាការប្រាក់ខ្ពស់ ដើម្បីបង់ថ្លៃអគ្គិសនី និងថ្នាំពេទ្យក្នុងខែឧសភា មិថុនា និងកក្កដា ។

ជាទូទៅ និយោជកបានមើលស្រាលចំពោះកម្រិតសីតុណ្ហភាពដែលបានប៉ះពាល់ដល់កម្មករ ។ អ្នកគ្រប់គ្រងរោងចក្រទាំងអស់នៃតំបន់ដាក្កាដែលបានសម្ភាស បានរាយការណ៍ពីវិធានការ ដើម្បីធ្វើឲ្យរោងចក្រត្រជាក់ ហើយអ្នកគ្រប់គ្រងប្រាំបីនាក់ក្នុងចំណោមដប់នាក់ដែលបានសម្ភាសបាននិយាយថា មិនមានការត្អូញត្អែរអំពីកម្តៅពីកម្មករ ឬសហជីពទេ ។

ការស្ទង់មតិរបស់កម្មករកម្ពុជាបង្ហាញថា យ៉ាងហោចណាស់ 25 ភាគរយ (ក្នុងចំណោមកម្មករ 200 នាក់ ដែលត្រូវបានសម្ភាស) បានរាយការណ៍ថា មានភាពតានតឹងដោយសារកម្តៅកើនឡើងនៅឆ្នាំ 2022 ហើយ 22 ភាគរយនៃកម្មករបាននិយាយថា ភាពតានតឹងដោយសារកម្តៅបានប៉ះពាល់ដល់សមត្ថភាពការងាររបស់ពួកគេ ។ នៅទីក្រុង ការ៉ាជី ប្រទេសប៉ាគីស្ថាន រលកកម្តៅកាន់តែមានគ្រោះថ្នាក់ ។ ក្រុមហ៊ុនរថយន្តសង្គ្រោះមួយនៅទីនោះបានរាយការណ៍ថា ជាងពាក់កណ្តាលនៃអ្នកស្លាប់ក្នុងរលកកំដៅឆ្នាំ 2018 គឺជាកម្មកររោងចក្រដែលរស់នៅក្នុងសង្កាត់ក្រីក្រជុំវិញទីក្រុងការ៉ាជី ។

## 3.0. តើច្បាប់ស្តីពីការងារការពារកម្មករពីការបំផ្លិចបំផ្លាញដោយអាកាសធាតុដែរឬទេ ?

តើច្បាប់ដែលការពារកម្មករពីកម្តៅ និងទឹកជំនន់ខ្លាំងនៅប្រទេសបង់ក្លាដែស កម្ពុជា ប៉ាគីស្ថាន និងវៀតណាម រឹងមាំប៉ុនណា ? កម្រិតកម្តៅខាងក្នុងអគារសម្រាប់រោងចក្រមិនមាននៅក្នុងច្បាប់នៅក្នុងប្រទេសបង់ក្លាដែស កម្ពុជា និងប៉ាគីស្ថានទេ។ ច្បាប់

ការងាររបស់ប្រទេសកម្ពុជាគឺខ្សោយជាងគេក្នុងក្រុម៖ មិនមានការកំណត់កម្រិតកម្តៅខាងក្នុងអគារ ហើយមិនមានលក្ខខណ្ឌតម្រូវឲ្យមាន ពេលសម្រាកមានប្រាក់ឈ្នួល ច្បាប់ឈប់សម្រាកឈឺមានប្រាក់ឈ្នួល ការបញ្ឈប់ពីការងារដែលទទួលបានប្រាក់ឈ្នួល ឬសិទ្ធិអំឡុងពេលឈប់ធ្វើការក្នុងពេលកូដកម្ម ដែលអនុញ្ញាតឲ្យនិយោជកគេចវេះកាតព្វកិច្ចបង់ប្រាក់បំណាច់ការងារមួយចំនួន ។

ច្បាប់ការងាររបស់ប្រទេសវៀតណាមគឺច្បាស់ជាងគេក្នុងចំណោមប្រទេសទាំងបួន ។ ប៉ុន្តែនៅក្នុងចំណោមប្រទេសទាំងបួនវិញ ការអនុវត្តច្បាប់គឺខ្សោយ ដោយយោងតាមកម្មករ និងអ្នកសង្កេតការណ៍ ។ តារាងនេះប្រៀបធៀបផ្នែកផ្សេងៗនៃច្បាប់ដែលមានសារៈសំខាន់សម្រាប់ការប្រែប្រួលអាកាសធាតុ និងជាពិសេសកម្តៅ ។

សម្រាប់សវនកម្មរោងចក្ររបស់យីហោធំៗវិញ កម្មវិធី Better Work របស់អង្គការ ILO មានស្តង់ដារច្បាស់លាស់បំផុត ។ ប៉ុន្តែក្រមប្រតិបត្តិរបស់យីហោសំលៀកបំពាក់មានភាពទន់ខ្សោយលើបញ្ហាអាកាសធាតុដែលប៉ះពាល់ដល់កម្មករ ។

| | បង់ក្លាដែស | កម្ពុជា | ប៉ាគីស្ថាន (ខេត្ត Sindh ) | វៀតណាម |
|---|---|---|---|---|
| **កម្តៅខាងក្នុងអគារ** | សីតុណ្ហភាព "កំណត់ត្រឹមកម្រិត ដែលអាចទទួលយកបាន" តម្រូវឲ្យមាន ទែម៉ូម៉ែត្រមួយក្នុងមួយបន្ទប់ធ្វើការ ។ | "ការងារដែលធ្វើឡើងក្នុងបរិយាកាសកម្តៅដែលមិនប៉ះពាល់ដល់សុខភាពកម្មករ... និយោជកត្រូវតែចាត់វិធានការកាត់បន្ថយកម្តៅឲ្យបានសមស្រប។" តម្រូវឲ្យមាន "ទែម៉ូម៉ែត្រច្រើននៅកន្លែងធ្វើការ"។ | រក្សាសីតុណ្ហភាពខាងក្នុងសម្រាប់ " លក្ខខណ្ឌសមហេតុផលនៃផាសុកភាព និង [ការការពារនៃ] របួសចំពោះសុខភាព" ដោយមានជញ្ជាំង និងដំបូលដែលត្រូវបានរចនាឡើង ដើម្បីធ្វើឲ្យសីតុណ្ហភាពមិនលើសពីនេះ ។ "សន្ទស្សន៍កម្តៅត្រឹមត្រូវ" កត់ត្រាបី ដងក្នុងថ្ងៃ ។ | សីតុណ្ហភាពនៅខាងក្នុងកន្លែងធ្វើការមិនគួរលើសពី 34°C, 32°C និង 30°C សម្រាប់ការងារស្រាល មធ្យម និងធ្ងន់ ។ សំណើមដែលមាន មិនគួរលើសពី 80% ។ ត្រូវមានកិច្ចសន្យារបស់និយោជកសម្រាប់ការវាយតម្លៃសីតុណ្ហភាព សំណើម ។ល។ |

| | | | | |
|---|---|---|---|---|
| **ចរន្តខ្យល់ចេញចូល ខាងក្នុងអគារ** | "ចំនួនបង្អួចដែលគ្រប់គ្រាន់ស្ថិតនៅទល់មុខគ្នាគ្រប់បន្ទប់ធ្វើការ" សម្រាប់ចរន្តខ្យល់ចេញចូល និង "កង្ហារបឺតខ្យល់នៅកន្លែងដែលមិនមានចរន្តខ្យល់ចេញ ចូល" ។ | "និយោជកត្រូវចាត់វិធានការដើម្បីធានាឲ្យមានចរន្តខ្យល់សមស្រប ។" | ការបើកឲ្យមានខ្យល់ចេញចូល "ក្នុងសមាមាត្រ 'ប្រាំហ្វីតការ៉េសម្រាប់មនុស្សម្នាក់ៗ" គឺត្រូវបានតម្រូវ "ដើម្បីទទួលយកការផ្គត់ផ្គង់ខ្យល់បរិសុទ្ធជាបន្តបន្ទាប់" ។ | "ខ្យល់ស្អាតបរិសុទ្ធត្រូវតែគ្រប់គ្រង [ផ្អែកលើ] បរិមាណមនុស្សនៅក្នុងបន្ទប់ តម្រូវការសម្រាប់កម្លាំងពលកម្មដោយដៃ ទំហំរោងជាង ការបំភាយជាតិពុល លក្ខខណ្ឌកម្តៅ [និង] ពន្លឺត្រូវតែគ្រប់គ្រាន់។" |
| **ទឹកស្អាតសម្រាប់បរិភោគ** | "ទឹកបរិសុទ្ធ" និងទឹកត្រជាក់សម្រាប់បរិភោគដោយកម្មករ "ផ្លាស់ប្តូរយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ" លុះណាតែប្រើ "ប្រព័ន្ធបន្សុទ្ធទំនើប" ។ | "កម្មករត្រូវតែទទួលបានការផ្គត់ផ្គង់ទឹកសម្រាប់តម្រូវការទាំងអស់របស់ពួកគេ នៅគ្រប់រដូវ។" | "ការផ្គត់ផ្គង់ទឹកស្អាតគ្រប់ចំនួន" នៅសីតុណ្ហភាពតិចជាង 32 អង្សាសេ "ឥតគិតថ្លៃ" "ក្នុងអត្រា 1 ហ្គាឡុងក្នុងកម្មករម្នាក់ ។" | និយោជកត្រូវផ្តល់ទឹកស្អាត 1.5 លីត្រ ដែលបានធ្វើតេស្ត "ក្នុងមនុស្សម្នាក់ ក្នុងមួយវេន ។" |
| **ពេលសម្រាក** | មិនលើសពី 6 ម៉ោង ដោយគ្មានការសម្រាកយ៉ាងហោចណាស់ 1 ម៉ោង ។ មិនលើសពី 5 ម៉ោងដោយគ្មានការសម្រាកយ៉ាងហោចណាស់កន្លះម៉ោង ។ | មិនលើសពី 8 ម៉ោង ក្នុងមួយថ្ងៃសម្រាប់ "ម៉ោងធ្វើការពេញ" ។ រយៈពេលធ្វើការត្រូវបានកំណត់ដោយសហគ្រាសនីមួយៗ ។ | មិនលើសពី 6 ម៉ោង ដោយគ្មានការសម្រាកយ៉ាងហោចណាស់ 1 ម៉ោង។ ឬ មិនលើសពី 5 ម៉ោង ដោយគ្មានការសម្រាកយ៉ាងហោចណាស់កន្លះម៉ោង ។ | ការងារប្រាំមួយម៉ោង ឬច្រើនជាងនេះត្រូវរាប់បញ្ចូលការសម្រាកយ៉ាងហោចណាស់កន្លះម៉ោង និងសម្រាក 45 នាទី សម្រាប់ការងារពេលយប់ ។ |
| **ពេលសម្រាកមាន ប្រាក់ឈ្នួល** | គ្មានស្តង់ដារច្បាស់លាស់ | គ្មានស្តង់ដារច្បាស់លាស់ | គ្មានស្តង់ដារច្បាស់លាស់ | រយៈពេលសម្រាកដែលត្រូវការស្របច្បាប់ត្រូវបានបង់ថ្លៃ និងរាប់ជា "ផ្នែកនៃ ម៉ោងធ្វើការ" ។ |
| **ឈប់ពីការងារក្នុងលក្ខខណ្ឌគ្រោះថ្នាក់** | គ្មានស្តង់ដារច្បាស់លាស់ | គ្មានស្តង់ដារច្បាស់លាស់ | គ្មានស្តង់ដារច្បាស់លាស់ | "កម្មករអាច បដិសេធមិនបំពេញការងារ ឬចាកចេញពីកន្លែងធ្វើការដែលវាបានបង្ហាញយ៉ាងច្បាស់ពីការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់អាយុជីវិត ឬសុខភាព ហើយមិនអាចតម្រូវឲ្យត្រឡប់/បន្តការងារវិញបានទេ រហូតដល់គ្រោះថ្នាក់ត្រូវបានលុបបំបាត់ ។ |

| | | | | |
|---|---|---|---|---|
| **ការបញ្ឈប់ពីការងារដែលទទួលបានប្រាក់ឈ្នួល** | កម្មករត្រូវទទួលបានប្រាក់ឈ្នួលសម្រាប់ការឈប់សម្រាកពី 1 ទៅ 3 ថ្ងៃ ប្រសិនបើមាន "អគ្គីភ័យ គ្រោះមហន្តរាយ ការបញ្ឈប់ការផ្គត់ផ្គង់ថាមពល និងជំងឺ រាតត្បាត" ប៉ុន្តែអាចត្រូវបានកាត់ចេញសម្រាប់ការឈប់ទាំងឡាយដែលមានរយៈពេលលើសពី 3 ថ្ងៃ ។ | មិនតម្រូវឲ្យមានការជូនដំណឹងអំពីការកាត់បុគ្គលិកជាមុនសម្រាប់ "ករណីប្រធានសក្តិ" ឬគ្រោះមហន្តរាយដែលបណ្តាលឲ្យមានការបំផ្លិចបំផ្លាញសម្ភារៈ ហើយធ្វើឲ្យវាមិនអាចបន្តការងារក្នុង រយៈពេលយូរបាន ។" | គ្មានស្តង់ដារច្បាស់លាស់ | យ៉ាងហោចណាស់ ប្រាក់ឈ្នួលអប្បបរមាត្រូវតែបង់សម្រាប់ "ករណីប្រធានសក្តិ" ឬ "ការបញ្ឈប់ពីការងារដោយបង្ខំ"។ |
| **ច្បាប់សម្រាកឈឺមាន ប្រាក់ឈ្នួល** | "កម្មករគ្រប់រូបមានសិទ្ធិដាក់ច្បាប់សម្រាកឈឺមាន ប្រាក់ឈ្នួលពេញ 14 ថ្ងៃ" ដោយគ្រាប់តែឲ្យ "គ្រូពេទ្យបញ្ជាក់ថាកម្មករនោះមានជំងឺ" | គ្មានស្តង់ដារច្បាស់លាស់ | "កម្មករគ្រប់រូបមានសិទ្ធិដាក់ច្បាប់ឈប់សម្រាកឈឺ 16 ថ្ងៃក្នុងមួយឆ្នាំ ដោយទទួលបានប្រាក់ឈ្នួលពេញ ។" | ច្បាប់សម្រាកឈឺដោយទទួលបានប្រាក់ឈ្នួលរហូតដល់ 180 ថ្ងៃក្នុងមួយឆ្នាំ ដោយមានការបញ្ជាក់ពីសុខភាព (ផ្អែកលើកម្រិត និងរយៈពេលនៃការរួមវិភាគទានក្នុងធានារ៉ាប់រងសង្គម)។ |

## 4.0 តើយើងធ្វើអ្វី?

យើងមានអនុសាសន៍សម្រាប់វិធានការ "សម្របខ្លួន" ដោយរដ្ឋាភិបាល និយោជក យីហោ និងអង្គការស្ថាប័នផ្សេងៗរបស់កម្មករ ។ បីចំណុចដែលមានសារៈសំខាន់បំផុត ។

- ឧស្សាហកម្មកាត់ដេរគួរតែវិនិយោគលើការសម្របខ្លួន មិនមែន "មកប្រមូលផល ហើយរត់ទៅ" ប្រទេសដែលមានហានិភ័យអាកាសធាតុតិចជាងនេះនោះទេ ។
- ប្រាក់ឈ្នួលខ្ពស់ និងប្រព័ន្ធគាំពារសង្គមដ៏ល្អសម្រាប់កម្មករ អាចជួយកម្មករ និងគ្រួសាររបស់ពួកគេឲ្យជៀសផុតពីផលប៉ះពាល់ដ៏អាក្រក់បំផុតនៃការបំផ្លិចបំផ្លាញដោយអាកាសធាតុ ។
- សហជីព និងអង្គការសិទ្ធិការងារគួរតែរួមបញ្ចូលការការពារពីផលប៉ះពាល់អាកាសធាតុ ដូចជាកម្តៅ និងទឹកជំនន់ ក្នុងការចរចាជាមួយនិយោជក និងយីហោធំៗ និងក្នុងការសន្ទនាជាមួយរដ្ឋាភិបាល និងបណ្តាសមាគមក្នុងឧស្សាហកម្មនេះ ។

អនុសាសន៍ផ្សេងទៀតរួមមាន៖

- ផ្លាស់ប្តូរម៉ោងធ្វើការ កម្រិតនៃកិច្ចខិតខំប្រឹងប្រែង ការសម្រាក និងជាតិទឹក ដោយផ្អែកលើស្តង់ដារសន្ទស្សន៍កម្តៅខាងក្នុងអគារ
- កំណត់ច្បាប់សម្រាប់ការប្រមូលប្រចាំថ្ងៃ ការរាយការណ៍ និងសកម្មភាពពីការយល់ដឹងលើសីតុណ្ហភាព និងសំណើមនៅក្នុងកន្លែងផលិតកម្មផ្សេងៗនៃរោងចក្រ
- ចាត់ទុកព្រឹត្តិការណ៍ឡើងកម្តៅ និងទឹកជំនន់ជាគ្រោះថ្នាក់នៃសុខភាព ដោយមានច្បាប់សម្រាកមានប្រាក់ឈ្នួលសម្រាប់ព្រឹត្តិការណ៍ទាំងនោះ និងជំងឺដែលពាក់ព័ន្ធ សិទ្ធិក្នុងការឈប់ធ្វើការងារ—ទាំងអស់ ដោយគ្មានការពិន័យដល់កម្មករឡើយ
- ត្រូវមានប្រព័ន្ធព្រមានជាមុន និងយុទ្ធនាការទ្រង់ទ្រាយធំសម្រាប់ភាពតានតឹងដោយសារកម្តៅ ឬទឹកជំនន់របស់កម្មករ

របាយការណ៍ពេញលេញពីសាកលវិទ្យាល័យ Cornell និង Schroders មានជាភាសាអង់គ្លេស តាមអាសយដ្ឋាន៖ https://www.ilr.cornell.edu/global-labor-institute ។